**Workshop Minute**
**Second National Farmer Forum**
**“Together to support smallholder farmers to adapt climate change for sustainable livelihood”**

The Forum was organized from 27 – 28 April 2011 in Phnom Penh participated by 408 people from different sectors include farmers, NGOs, Government, Development Partners, and Private sector. The participants have discussed and raised their success and failures to climate change adaptation to the Ministers representatives from Ministry of Rural Development.

# កំណត់ហេតុ
# វេទិកាកសិករថ្នាក់ជាតិលើកទី ២
# ស្តីពី “រួមគ្នាជួយកសិករខ្នាតតូចបន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុដើម្បីនិរន្តរភាពជីវភាព”

**ទីកន្លែង** : **សណ្ឋាគារភ្នំពេញ**

**ពេលវេលា** : **ថ្ងៃទី ២៧-២៨ ខែ មេសា ឆ្នាំ ២០១១**

**រៀបចំដោយ** : **ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៏វិស័យកសិកម្ម និង ជនបទ**

**សហការរៀបចំដោយ** : Caritas Cambodia, Catholic Relief Service, Oxfam, Christian Aid, NGO Forum on Cambodia, CEDAC, Srer Khmer, and Padek

**សមាជិកចូលរួមកម្មវិធី** : **៤០៨ នាក់**

**បើកកម្មវិធីដោយ** : **ឯកឧត្តម តាវ សេងហួ**

**បិទកម្មវិធីដោយ** : **ឯកឧត្តម យឹម ឆៃលី**

នៅថ្ងៃទី ២៧-២៨ ខែ មេសា ឆ្នាំ ២០១១ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៏វិស័យកសិកម្ម និង ជនបទ បានរៀបចំវេទិកាកសិករថ្នាក់ជាតិលើកទី២ នៅសណ្ឋាគារភ្នំពេញក្រោមការចូលរួមសហការរៀបចំពីបណ្តា ក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៏ និង ក្រុមហ៊ុនឯកជន ដើម្បីផ្តល់ឱកាសអោយកសិករ ស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលទាំង ២៤ ខេត្តក្រុង ដៃគូអភិវឌ្ឍន៏ និងវិស័យឯកជន បានធ្វើការពិភាក្សាបែបវិមជ្ឈការដើម្បីចែករំលែកបទពិសោធន៏ភាពជោគជ័យ កត្តាប្រឈម និង ឧបសគ្គនានាដែលរាំងស្ទះកសិករក្នុងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងដើម្បីចងក្រងនូវមតិយោបល់ និង អនុសាសន៏ផ្សេងៗដែលអាចជួយដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ និង កសិករក្នុងការបន្សុាំបានល្អ។ កិច្ចពិភាក្សាដែលមានរយៈពេល ២ថ្ងៃបានប្រព្រឹត្តទៅប្រកបដោយបរិយាកាសល្អ និងទទួលបាននូវលទ្ធផលជាផ្លែផ្កាគួរអោយកត់សំគាល់តាមរយៈការពិភាក្សាលើចំណុចសំខាន់ៗដូចខាងក្រោម។

## I. កម្មវិធីថ្ងៃទី ២៧ មេសា ២០១១

### ១. មតិស្វាគមន៏ និង ប្រកាសគោលបំណងអង្គវេទិកាដោយលោក គីម រតនា នាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជា

ជាកិច្ចចាប់ផ្តើម លោក គីម រតនា បានធ្វើបទសុន្ទរៈកថាស្វាគមន៏ដល់អង្គពិធី និង គណៈអធិបតី និង ប្រកាសអំពីគោលបំណងរបស់អង្គវេទិកាដែលមានរយៈពេល ២ថ្ងៃនេះ។ គោលបំណងនៃអង្គវេទិការយៈពេល ២ថ្ងៃនេះគឺដើម្បីផ្តល់ឱកាសដល់កសិករ និង ស្ថាប័នដែលពាក់ព័ន្ធមួយចំនួនបានធ្វើការចែករំលែកបទពិសោធន៏ជោគជ័យដល់គ្នា និង ពិភាក្សាពីផលប៉ះពាល់

ការប្រឈម និង ឧបសគ្គ ដែលពួកគាត់កំពុងជួបប្រទះក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និង ដើម្បីធ្វើការចងក្រងនូវអនុសាសន៍ទាំងឡាយពីអង្គវេទិកា ដែលអាចជួយដល់កសិករខ្នាតតូចបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុបានកាន់តែប្រសើរ។ លោកបានមានប្រសាសថា ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុដូចជា កំណើនសីតុណ្ហភាព របបទឹកភ្លៀងមិនទាន់ទាត់ និង រដូវកាលមិនទៀងទាត់ បានបង្កនូវគ្រោះមហន្តរាយធម្មជាតិមួយចំនួនរួមមាន គ្រោះរាំងស្ងួត ទឹកជំនន់ និង ខ្យល់ព្យុះជាដើម ដែលជះឥទ្ធិពលអវិជ្ជមានដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសវិស័យកសិកម្មខ្នាតតូច។ ប្រទេសកម្ពុជាក្នុងទសវត្សរ៍ចុងក្រោយនេះ បានរងនូវវិបត្តិមួយចំនួនដូចជា វិបត្តិសេដ្ឋកិច្ច និង កំណើនតម្លៃប្រេង និងអាហារ លើសពីនេះទៀតកម្ពុជាក៏ជាប្រទេសមួយដែលកំពុងតែទទួលរងនូវផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុផងដែរ ដែលប្រការនេះបានជះឥទ្ធិពលអវិជ្ជមានដល់កសិករខ្នាតតូច។ ដូច្នេះហើយយើងសង្ឃឹមថា វេទិកានេះនឹងផ្តល់ឱកាសអោយយើងទាំងអស់គ្នាបានធ្វើការរួមគ្នាកាន់តែមានប្រសិទ្ធភាព ដើម្បីឈានទៅរកនូវជំរើសនានាក្នុងការជួយកសិករដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

## ២. សុន្ទរកថាបើកអង្គវេទិកាដោយឯកឧត្តម តាវ សេងហួ

ឯកឧត្តមបានសំដែងនូវសេចក្តីរីករាយ និង កោតសរសើរចំពោះកិច្ចសហការរបស់ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានបង្កើតនូវកម្មវិធីនេះឡើង ដើម្បីអោយកសិករ និង អ្នកពាក់ព័ន្ធដទៃទៀតមានឱកាសពិភាក្សាគ្នាដោយផ្ទាល់ ដើម្បីឈានទៅរកអនុសាសន៍សមស្របដែលអាចជួយដល់កសិករក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការចូលរួមយ៉ាងសកម្មពីសំណាក់កសិករ និងស្ថាប័នពាក់ព័ន្ធក្នុងកម្មវិធីនេះ សបញ្ជាក់អោយឃើញពីស្មារតីចូលរួមរបស់ប្រជាពលរដ្ឋខ្មែរក្នុងការដោះស្រាយបញ្ហាសង្គម និងសេដ្ឋកិច្ច ដើម្បីឈានទៅរកការកាត់បន្ថយភាពក្រីក្រប្រកបដោយជោគជ័យ។ ឯកឧត្តមក៏បានលើកឡើងផងដែរថារាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ និងប្តេជ្ញាចិត្តខ្ពស់ក្នុងការលើកស្ទួយវិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជាហើយបានចាត់ទុកវិស័យនេះជាកត្តាសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ តាមរបាយការណ៍ថ្នាក់ជាតិកាលពីឆ្នាំ ២០១០ កម្ពុជានៅសល់ស្រូវសរុបជាង ៣៧០ ពាន់តោន និង នៅសល់អង្ករចំនួន ២៥០ ពាន់តោន។ ដោយឡែក បច្ចុប្បន្នឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុបានកំពុងប៉ះពាល់លើវិស័យកសិកម្ម និងកត្តាពាក់ព័ន្ធនានាដូចជាធនធានទឹក ផលនេសាទ និង សុខភាពប្រជាពលរដ្ឋផងដែរ។ ឆ្លើយតបនឹងបញ្ហានេះ រដ្ឋាភិបាលកម្ពុជាបានជំរុញការអនុវត្តន៍នូវគោលនយោបាយផ្សេងៗដូចជា គោលនយោបាយអភិវឌ្ឍន៍ស្អាត ជំរុញការប្រើប្រាសថាមពលករកើតឡើងវិញ ជំរុញអោយមានការសន្សំសំចៃអគ្គិសនី ការប្រើប្រាស់ឡជីវឧស្ម័ន ចៀសវាងការកាប់បំផ្លាញព្រៃឈើ ហើយចូលរួមដាំព្រៃឈើឡើងវិញ និង បន្តធ្វើការបញ្ជ្រាបចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់របស់វា។ *ឯកឧត្តមក៏បានផ្តល់នូវគំនិតយោបល់ថា អង្គការក្រៅរដ្ឋាភិបាលគួរយកចិត្តទុកដាក់លើការរៀបចំយុវជនកសិករ ពង្រឹងសមត្ថភាព និង ការចូលរួមរបស់ពួកគេដើម្បីត្រៀមអនុវត្តន៍ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជាតិតទៅមុខទៀត*។ ជាចុងក្រោយឯកឧត្តម បានថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ ហើយបានរំពឹងទុកថា ការពិភាក្សារយៈពេលពីរថ្ងៃនេះនឹងផ្តល់នូវលទ្ធផលជាផ្លែផ្កា ដែលអាចជួយដល់កសិករដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និង ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាទៅតាមទិសដៅរបស់រដ្ឋាភិបាលដែលបានកំណត់ ១% ក្នុងមួយឆ្នាំ និង សំរេចអោយបាននូវការនាំចេញអង្កររហូតដល់ទៅ ១លានតោននៅក្នុងឆ្នាំ ២០១៥។

## ៣. បទបង្ហាញរបស់កសិករអំពីកត្តាជោគជ័យ និង ការប្រឈមក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

តំណាងកសិករទាំង ២៤ខេត្តក្រុងចំនួន ២រូបបានឡើងធ្វើការបកស្រាយអំពីគំនិតយោបល់របស់កសិករទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលមតិយោបល់នេះជាលទ្ធផលដែលបានមកពីការធ្វើ កិច្ចពិភាក្សាជាមុន ជាមួយក្រុមកសិករនៅពាតំបន់ គឺតំបន់ខ្ពង់រៀប តំបន់ឆ្នេរ និង តំបន់ទំនាបនៅក្នុងប្រទេសកម្ពុជា ក្នុងខែ មេសា ឆ្នាំ ២០១១។ បទបង្ហាញនេះបានឆ្លុះបញ្ចាំងពី

បញ្ហាប្រឈមរបស់កសិករដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ ភ្លៀងខ្មៅ ការស្រកចុះលឿនជាងមុននៃទន្លេមេគង្គ ទន្លេរមតូច ដែលធ្វើអោយតំបន់ជុំវិញខ្វះដីល្បាប់ សីតុណ្ហភាពផ្លាស់ប្តូរមិនប្រក្រតី រដូវកាលមិនទៀងទាត់ រន្ទះច្រើន ទឹកឡើងកំដៅ ការកើនកំពស់ទឹកសមុទ្រ ដែលធ្វើអោយទឹកប្រៃហូរចូលស្រែកសិករ ជំងឺថ្មីៗដែលកើតមានលើដំណាំ និង ការកើតឡើងនូវសត្វល្អិតច្រើន។ លើសពីនេះទៅទៀត កសិករក៏ជួបប្រទះបញ្ហាមួយចំនួនដែលជាបញ្ហាសង្គមនិងសេដ្ឋកិច្ចដូចជា ខ្វះទឹកសំរាប់កសិកម្ម បច្ចេកទេសកសិកម្មនៅមានកំរិត ខ្វះទំនាក់ទំនងនិងចំណេះដឹងទីផ្សារ ខ្វះបច្ចេកទេសកែច្នៃ ការប្រើប្រាស់ជីគីមីមិនបានត្រឹមត្រូវ ខ្វះទុន អត្រាការប្រាក់ខ្ពស់ និង បញ្ហាការបាត់បង់ដីធ្លី។ ទាក់ទិននឹងបញ្ហានេះដែរ កសិករបានលើកឡើងនូវសំណូមពរមួយចំនួនអំពីតំរូវការរបស់ពួកគាត់រួមមាន សូមអោយមានការបង្កើនហេដ្ឋារចនាសម្ព័ន្ធជនបទ និងធារាសាស្ត្រ ចំណេះដឹងក្នុងការជ្រើសរើសនិងប្រើប្រាស់ពូជល្អនិងជីមានគុណភាព ធ្វើអោយមានភាពប្រសើរចំពោះសំភារៈកសិ កម្ម និង បច្ចេកទេសកសិកម្ម និង កិច្ចសហការល្អរវាងរដ្ឋបាលមូលដ្ឋាននិងប្រជាពលរដ្ឋក្នុងការអនុវត្តន៍គំរោងអភិវឌ្ឍន៍ផ្សេងៗ ចូលរួមគ្រប់គ្រងធនធានធម្មជាតិព្រៃឈើ និងបញ្ឈប់ក្រុមហ៊ុនសម្បទានណាដែលធ្វើអោយប៉ះពាល់ដល់ជីវភាពរបស់ប្រជាជន បង្កើនព័ត៌មានទីផ្សារ ចំណេះដឹងរបស់ស្ត្រី កសិករមានចំណេះដឹងពីគណនេយ្យសាមញ្ញ និង ការវិភាគសេដ្ឋកិច្ចសាមញ្ញ ទាក់ទាញវិនិ យោគទន់បន្ថែម អនុវត្តន៍គោលការណ៍ និង ច្បាប់នានាដែលលើកកំពស់សេដ្ឋកិច្ចរបស់ប្រជាកសិករ។

## សំនួរ_ចម្លើយ

***១. តើភ្លៀងខ្មៅដែលកសិករបានលើកឡើងកើតមាននៅកន្លែងណា? ពេលណា?***

**ចម្លើយ:** ករណីនេះកើតឡើងនៅស្រុកបារាយ ខេត្តកំពង់ធំ។ កសិករបានសង្កេតឃើញថា ក្រោយពេលបីថ្ងៃដែលមានភ្លៀងពណ៌ខ្មៅនោះ បន្លែ និងដំណាំរបស់ពួកគាត់មានការរលួយខូចខាត។ ក្រសួងបរិស្ថានបានចូលរួមបកស្រាយបញ្ជាក់អំពីព្រឹត្តិការណ៍នេះថា នេះប្រហែលជាបណ្តាលមកពីបញ្ហាបរិស្ថានដែលយើងអោយឈ្មោះថាភ្លៀងអាស៊ីត ដែលបណ្តាលមកពីការបំភាយឧស្ម័នពុល។ ហើយនេះក៏ប្រហែលជាសញ្ញាណដំបូងនៃភ្លៀងអាស៊ីតនៅក្នុងប្រទេសកម្ពុជា។ ក្រសួងបរិស្ថានបានសន្យានឹងធ្វើការស្រាវជ្រាវលើករណីនេះ។

***២. តើហេតុអ្វីបានជាជនជាតិដើមឈប់ធ្វើកសិកម្មវិលជុំ?***

**ចម្លើយ:** នេះដោយសារមានការហាមឃាត់ពីសំណាក់រដ្ឋាភិបាល និង ក្រុមហ៊ុនវិនិយោគទន់មួយចំនួនបានរំលោភយកដីរបស់ប្រជាកសិករ..... តើនេះជាការអភិវឌ្ឍន៍ដើម្បី ជួយ ឬ ជាការបង្កបញ្ហាដល់ប្រជាពលរដ្ឋ?

***៣. សូមអោយតំណាងកសិករបញ្ជាក់អោយបានច្បាស់លាស់ពីបញ្ហាខ្វះធនធានទឹក?***

**ចម្លើយ:** សូមបញ្ជាក់ថាពាក្យថាខ្វះធនធានទឹកនេះគឺសំដៅដល់កន្លែងមួយចំនួនដែលពុំទាន់មានទឹកនៅឡើយ ហើយយើងក៏ទទួលស្គាល់ដែរថាកន្លែងខ្លះត្រូវបានអភិវឌ្ឍន៍និងកសាងធនធានទឹកហើយ ប៉ុន្តែកន្លែងខ្លះទៀតនៅជាបញ្ហាប្រឈមនៅឡើយ។

## ៤. គោលនយោបាយស្តីពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

តំណាងពីក្រសួងពាក់មួយចំនួនដូចជា ក្រសួងបរិស្ថាន ក្រសួងធនធានទឹក ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងកិច្ចការនារី បានធ្វើបទបង្ហាញលើការប្រែប្រួលអាកាសធាតុដែលកំពុងប៉ះពាល់ដល់ប្រទេសកម្ពុជា និង ផែនការរបស់រដ្ឋាភិបាល។ តំណាងពីគ្រប់ក្រសួងខាងលើបានលើកឡើងនូវលទ្ធផល និង ផែនការរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនិងបញ្ហាការប្រែប្រួលអាកាសធាតុ។ បទបង្ហាញបានបញ្ជាក់អោយឃើញថា បច្ចុប្បន្នមានភស្តុតាងជាច្រើនដែលបង្ហាញ

ថាកម្ពុជាកំពុងតែទទួលរងនូវផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលគំរាមកំហែងដល់ជីវភាពរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែលប្រកបរបរកសិកម្មនៅទីជនបទ ក្នុងនោះផលប៉ះពាល់មានដូចជា កំរិតកំដៅកើនឡើង របបទឹកភ្លៀងប្រែប្រួលរដូវកាលមិនទៀងទាត់ គ្រោះរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ ដែលបង្កអោយប្រជាពលរដ្ឋបាត់បង់ទ្រព្យសម្បត្តិបាត់បង់ទិន្នផលដំណាំជាពិសេសទិន្នផលស្រូវ ការរំខានពីកត្តាសត្វល្អិត និង កត្តាជម្ងឺផ្សេងៗ។ ឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះក្រសួងពាក់ព័ន្ធក៏ដូចជារដ្ឋាភិបាលបានដាក់ចេញនូវយន្តការនានារមួយចំនួនដើម្បីបន្តពង្រឹងនិង ជួយដល់កសិករក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលក្នុងរួមមានដូចជា វិធានការនិងគោលនយោបាយកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់អំពាវនាវអោយបណ្តាប្រទេសអភិវឌ្ឍន៏អនុវត្តន៏ការផ្តល់ជំនួយអោយបាន ១.៥% នៃ GDP របស់ខ្លួន ដែលក្នុងនោះ ៧0%សំរាប់កម្មវិធីបន្សាំការជំរុញការអនុវត្តន៏អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិផ្សេងៗស្តីពីការប្រែប្រួលអាកាសធាតុ ការលើកទឹកចិត្តនិងជំរុញការអភិវឌ្ឍន៏ស្អាត ការពង្រឹងស្ថាប័នដែលសំដៅជួយលើការអនុវត្តន៏ការបន្សាំ ដាក់បញ្ចូលការប្រែប្រួល អាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៏ជាតិ បន្តការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាដែលឆ្លើយតបនឹង តម្រូវការរបស់ប្រជាពល រដ្ឋក្នុងការបន្សាំដូចជា ប្រព័ន្ធធារាសាស្រ្ត ជំរុញការអនុវត្តន៏ច្បាប់ និង គោលនយោបាយការគ្រប់គ្រង ធនធានទឹក និង ការគ្រប់គ្រងប្រព័ន្ធព័តិមានធនធានទឹកនិងឧតុនិយម ដើម្បីផ្តល់ព័តិមានដល់ប្រជាពលរដ្ឋ បន្តកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ បង្កើនបច្ចេកទេសកសិកម្ម ធ្វើយ៉ាងណាអោយអត្រាការប្រាក់មានកំរិតទាប ដែលអាចទទួលយកបាន បន្តផ្សព្វផ្សាយ និង បង្កើនចំណេះដឹងរបស់ប្រជាពលរដ្ឋទាក់ទងនិងបញ្ហាការប្រែប្រួលអាកាសធាតុ និង ជំរុញការចូលរួមរបស់រដ្ឋាភិបាល ប្រជាពលរដ្ឋ វិស័យឯកជន និង ដៃគូអភិវឌ្ឍន៏ក្នុងការកសាងសមត្ថភាពដើម្បីបន្តអភិវឌ្ឍន៏ប្រទេស។ ទន្ទឹមនិងការដាក់ចេញនូវផែនការទាំង នេះរដ្ឋាភិបាលក៏មានបញ្ហាប្រឈមមួយចំនួនដែរដូចជាការខ្វះខាតថវិកា បច្ចេកទេស និង ការចូលរួមក្នុងការអនុវត្តន៏គំរោង។

## សំនួរ_ចម្លើយ

***១. តើគំរោងលក់កាបូនរបស់ក្រសួងបរិស្ថានមានដំណើរការដល់ណាហើយ?***

វាគឺជាគំរោងកាត់បន្ថយការបាត់បង់ព្រៃឈើ (RED) គោលបំណងគឺដើម្បីអោយប្រទេសអភិវឌ្ឍន៏ផ្តល់នូវថវិកាដល់ប្រទេសកំពុងអភិវឌ្ឍថែរក្សាព្រៃឈើ នៅប្រទេសកម្ពុជាគេបានអនុវត្តន៏គំរោងសាកល្បងនៅខេត្តឧត្តរមានជ័យ តែគំរោងនេះមិនទាន់ចេញជាផ្លូវការនៅឡើយទេ។

***២. តើ Technical Working Group ទៅលើថាមពលនិងព្រៃឈើមានស្ថាប័នណាខ្លះចូលរួម? និងដឹកនាំដោយអ្នកណា?***

គណៈកម្មការនេះគ្រប់គ្រងដោយសម្តេច ហ៊ុន សែន ហើយក្រសួងបរិស្ថានជាអ្នកអនុវត្តគំរោង និង មានការចូលរួមពីក្រសួងពាក់ព័ន្ធរួមមាន ក្រសួងឧស្សាហកម្មរ៉ែនឹងថាមពល និង ក្រសួងកសិកម្ម ។ល។

***៣. តើយើងមានវិធានណាខ្លះដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់?***

វិធានការរួមមានៈ ដាំព្រៃឈើ បន្ថយការប្រើប្រាស់ប្រេងឥន្ទនៈ ការប្រើប្រាស់ថាមពលកកើតឡើងវិញ ការដាំស្រូវស្រាល និង សកម្មភាពសន្សំសំចៃថាមពលផ្សេងៗទៀត។

## ៥. កិច្ចពិភាក្សាតុមូលៈ គណៈកម្មការផ្តល់យោបល់អំពីបញ្ហាប្រឈមរបស់កសិករ

ឯកឧត្តម វ័ន្ធ វីរៈ ធ្វើការសម្របសម្រួលកិច្ចពិភាក្សាតុមូលដែលមានការចូលរួមពីសំណាក់ ក្រុមប្រឹក្សាស្តារវិស័យកសិកម្មនិងអភិវឌ្ឍន៏ជនបទ ក្រសួងកិច្ចការនារី ធនាគារអភិវឌ្ឍន៏អាស៊ី ក្រុមហ៊ុនម៉ុងឬទ្ធីគ្រុប និង តំណាងអង្គការក្រៅរដ្ឋាភិបាល Oxfam ។ កិច្ចពិភាក្សាបានលើកឡើងនូវចំនុចសំខាន់មួយចំនួនទាក់ទិននឹងបញ្ហាសន្តិសុខស្បៀងនិងការប្រែប្រួលអាកាសធាតុ

បញ្ហារបស់ស្ត្រី ប្រឈមនឹងការប្រែប្រួលអាកាសធាតុ សកម្មភាពចូលរួមរបស់វិស័យឯកជន និង តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការជួយកសិករធ្វើការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ កម្ពុជាជាប្រទេសដែលងាយរងគ្រោះជាងគេពីការប្រែប្រួល អាកាសធាតុ ដោយសារតែយើងពឹងផ្អែកទាំងស្រុងលើវិស័យកសិកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ប្រជាជនជាង៨០ភាគរយប្រកបរបរកសិកម្ម និង ពឹងផ្អែកលើធនធានព្រៃឈើ។ យុទ្ធសាស្ត្រមួយចំនួនដើម្បីបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានដាក់ចេញដោយរដ្ឋាភិលបាលដូចជាៈ កែរលំអរការគ្រប់គ្រងទឹកនិងប្រព័ន្ធធារាសាស្ត្រ បង្កើនផលិតភាព (ការធានារាប់រងផលដំណាំ) ប្រើប្រាស់ពូជដែលសមស្រមតាមកាលៈទេសៈនៃអាកាសធាតុនិងរដូវកាល ធ្វើពិពិត្តកម្មកសិកម្ម (ដាំដំណាំច្រើនមុខ) ផែនការដីធ្លី បង្កើនធនាគារស្បៀង ជំរុញអោយមានការគ្រប់គ្រងធនធានធម្មជាតិ ជំរុញសមត្ថភាពត្រៀមបង្កាពង្រីកការប្រើប្រាស់ទឹកស្អាត និង បង្កើតប្រព័ន្ធសុវត្ថិភាពសង្គម។ ក្នុងនោះការដោះស្រាយបញ្ហាប្រឈមរបស់កសិករស្ត្រីក៏ជាកត្តាមួយដែលត្រូវយកចិត្តដាក់អោយបានជិតដល់ផងដែរពីសំណាក់ក្រសួងសមី និង បណ្តាក្រសួងដែលពាក់ព័ន្ធ។ បច្ចុប្បន្នកសិករជាស្ត្រីមានចំនួន ៥.៥ លាននាក់ ក្នុងនោះមាន ៥៥%មិនបានបញ្ចប់ថ្នាក់បឋមសិក្សា ហើយមានស្ត្រីត្រឹមតែ ១០% ប៉ុណ្ណោះដែលបានទទួលព័ត៌មានកសិកម្ម។ សព្វថ្ងៃក្រសួងកិច្ចការនារីដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញ និង លើកកំពស់ Gender តាមរយៈការអនុវត្តន៏គំរោងនារីរតនៈ និង ការផ្សព្វផ្សាយអប់រំតាមរយៈគំរោងផ្សេងៗទៀតដើម្បីជំរុញការចូលរួមរបស់ស្ត្រីនៅក្នុងការ ធ្វើសេចក្តីសំរេចចិត្ត និង លើកកំពស់ការយល់ដឹងរបស់ស្ត្រីពីការប្រែប្រួលអាកាសធាតុនិងឥទ្ធិពលរបស់វា។

ដៃគូអភិវឌ្ឍន៏ក៏បានបង្ហាញនូវគំរោងមួយចំនួនដែលពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ធនាគារអភិវឌ្ឍន៏អាស៊ី បច្ចុប្បន្នបានផ្តល់ជំនួយទៅលើគំរោងកម្មវិធីសាកល្បងសំរាប់ការបន្សុំានឹងបញ្ហាការប្រែប្រួលអាកាសធាតុហៅកាត់ថា (PPCR) ដែលមានទឹកប្រាក់សរុបប្រហែលជាង ១០០លានដុល្លារសំរាប់ពីរដំណាក់កាល ក្នុងនោះ ៥០% ជាជំនួយឥតសំណង និង ៥០% ទៀតជាប្រាក់កម្ចីដែលមានលក្ខខណ្ឌទាប។ ជំនួយនេះនឹងផ្តោតទៅលើវិស័យសំខាន់៣គឺ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និង ធនធានទឹក។

វិស័យឯកជនវិញដែលបានការចូលរួមធ្វើបទបង្ហាញពីសំណាក់តំណាងរបស់ក្រុមហ៊ុនម៉ុងឬទ្ធីបានបង្ហាញថា សព្វថ្ងៃក្រុមហ៊ុនកំពុងតែពង្រីកសកម្មភាពរបស់ខ្លួនពាក់ព័ន្ធនឹងវិស័យកសិកម្ម (ដំណាំដូងប្រេង កៅស៊ូ អាកាស្យា កសិដ្ឋានចិញ្ចឹមជ្រូក-គោ និង រោងចក្រផលិតជីកំប៉ុស្ត) ដែលនាំអោយមានតម្រូវការពលកម្មខ្ពស់ ហើយក្រុមហ៊ុនសង្ឃឹមថាការពង្រីកសកម្មភាពនេះនឹងជួយបង្កើតការងារដល់ប្រជាពលរដ្ឋខ្មែរបន្ថែមទៀត ដើម្បីចូលរួមកាត់បន្ថយចំណាកស្រុក និងរួមចំណែកជួយពួកគាត់ដើម្បីបន្សុំានឹងការប្រែប្រួលអាកាសធាតុ។ ក្រុមហ៊ុនក៏បានចូលរួមអនុវត្តន៏នូវការអភិវឌ្ឍន៏ស្អាតតាមរយៈការប្រើប្រាស់ឡជីវឧស្ម័នដើម្បីផលិតអគ្គិសនីសំរាប់ផ្គត់ផ្គង់ដល់ការផលិតនៅក្នុងរោងចក្រផងដែរ។

តំណាងពីអង្គការក្រៅរដ្ឋាភិបាលបានធ្វើបទបង្ហាញបញ្ជាក់អំពីតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការងារជួយកសិករ បន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាលគឺធ្វើជាអ្នកសម្របសម្រួល និងភ្ជាប់ទំនាក់ទំនង រវាងរដ្ឋាភិបាល និងសហគមន៏ ដើម្បីពិភាក្សាអំពីគំនិតយោបល់ និងដំណោះស្រាយផ្សេងៗដែលជារបស់សហគមន៏ពាក់ព័ន្ធនឹងការបន្សុំា អង្គការក្រៅរដ្ឋាភិបាលគួរធ្វើយ៉ាងណាអោយមានការចូលរួមរវាងរដ្ឋាភិបាល ជាមួយនឹងប្រជាពលរដ្ឋ (យើងជួយអោយពួកគាត់ធ្វើការក្នុងភាពជាដៃគូ) ដើម្បីអោយអ្នកដែលទទួលរងគ្រោះបានបញ្ចេញមតិយោបល់ និងរកដំណោះស្រាយដែលសម ស្របសំរាប់ពួកគេ។ លោកក៏បានបញ្ជាក់ផងដែរថាថវិកាពីប្រទេសអភិវឌ្ឍន៏ក្នុងការជួយដល់

បញ្ហាការប្រែប្រួលអាកាសធាតុ ពុំមែនជាជំនួយអភិវឌ្ឍន៍ទេ ប៉ុន្តែវាជាថវិកាដែលប្រទេសកម្ពុជាគួរតែទទួលបានដើម្បីយកទៅអនុវត្តន៍ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដែលបណ្តាល មកពីការកើនឡើងនូវសកម្មភាពផ្សេងៗលើពិភពលោកដែលប៉ះពាល់ដល់បរិស្ថាន។

**សំនួរ_ចម្លើយ**

***១. ការធ្វើធានារ៉ាប់រងដំណាំមានទំនាក់ទំនងអ្វីនឹងការប្រែប្រួលអាកាសធាតុ? តើនរណាជាអ្នកទទួលខុសត្រូវ?***

**ចម្លើយ:** ផែនការផ្តល់ធានារ៉ាប់រងនេះមិនទាន់បានអនុវត្តនៅឡើយទេ នេះគឺជាគំនិតដែលកំពុងតែធ្វើការសិក្សា។

***២. តើADB បានកំណត់ខេត្តទិសដៅសំរាប់គំរោងអភិវឌ្ឍរបស់ខ្លួនហើយឬនៅ?***

**ចម្លើយ:** ការកំណត់តំបន់គោលដៅ គឺជាតួនាទីរបស់រដ្ឋាភិបាលដែលជាអ្នកលើកឡើងនិងដឹកនាំគំរោង

## II. កម្មវិធីថ្ងៃទី ២៨ មេសា ២០១១

នៅថ្ងៃទី២សមាជិកទាំងអស់ចូលរួមធ្វើការពិភាក្សាជាក្រុមដើម្បីឆ្លើយទៅនិងសំនួរសំខាន់៣ដែលពាក់ព័ន្ធនិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ សំនួរទាំងបីនោះគឺ:

១. តើអ្វីខ្លះជាភាពជោគជ័យ ការប្រឈម និង ឧបសគ្គរាំងស្ទះដល់ការអនុវត្តន៍ការងារ (ជាមួយកសិករ) ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ?

២. តើអ្វីខ្លះដែលយើងអាចធ្វើបានដើម្បីជំនះរាល់ការប្រឈម និង ឧបសគ្គទាំងឡាយដែលរាំងស្ទះដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ?

៣. តើកត្តាអ្វីខ្លះដែលអាចនាំយើងអោយសំរេចបានជោគជ័យ?

អ្នកចូលរួមទាំងអស់ត្រូវបានបែងចែកជា ក្រុមកសិករ ក្រុមរដ្ឋាភិបាល និង ក្រុមអង្គការមិនមែនរដ្ឋាភិបាលដើម្បីធ្វើការពិភាក្សាលើចំនុចទាំង៣ខាងលើទៅតាមក្រុមនិមួយៗ ហើយធ្វើបទបង្ហាញលទ្ធផលទៅក្រុមធំ។ ក្រុមពិភាក្សាបានបង្ហាញនូវលទ្ធផលដូចខាងក្រោម:

### ១. *បទបង្ហាញពីលទ្ធផលពិភាក្សារបស់អង្គការមិនមែនរដ្ឋាភិបាល*

**កត្តាជោគជ័យ:** អង្គការក្រៅរដ្ឋាភិបាលបានកត់សំគាល់ឃើញពីការ កើនឡើងនៃចំណេះដឹងលើការប្រែប្រួលអាកាសធាតុ ដែលជាលទ្ធផលពីការអនុវត្តន៍ការផ្សព្វផ្សាយរបស់អង្គការមិនមែនរដ្ឋាភិបាល ភាពប្រសើរឡើងនៃការកសាងហេដ្ឋារចនា សម្ព័ន្ធជនបទ (អណ្តូងទឹក ទំនប់ ប្រឡាយ ស្រះធម្មជាតិ គ្រាប់ពូជ ផ្តល់បច្ចេកទេសដល់កសិករ និង ការកសាងសមត្ថភាព) ក្រោមកិច្ចសហការរវាងរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលទោះបីជានៅមានកំរិតក្តី។

**បញ្ហាប្រឈម:** ទន្ទឹមនឹងភាពជោគជ័យក៏មានកត្តាប្រឈមមួយចំនួនដែលអង្គការមិនមែនរដ្ឋាភិបាលបាននិងកំពុងជួបប្រទះដូចជា ការប្រែប្រួលអាកាសធាតុ ចំណាកស្រុករបស់ប្រជាជន បញ្ហាជំលោះនិងទំនាស់ដីធ្លី សមត្ថភាពរបស់បុគ្គលិក ជំលោះព្រំដែន ខ្វះខាតថវិកា និង ថវិកាមិនទៀងទាត់សំរាប់ការអភិវឌ្ឍន៍គំរោង ការចូលរួមពីប្រជាជនពុំទាន់បានទូលំទូលាយ សកម្មភាពរបស់អង្គការមានភាពត្រួតស៊ីគ្នា ដែលកត្តាទាំងនេះធ្វើអោយរាំងស្ទះដល់ការអនុវត្តន៍ការបន្សាំ។

**អនុសាសន៍:** បន្តពង្រឹងការផ្សព្វផ្សាយ និង អប់រំបន្ថែមពាក់ព័ន្ធនិងការប្រែប្រួលអាកាសធាតុ ជំរុញនិងបង្កើនការចូលរួមរបស់ប្រជាជនជាមួយរដ្ឋាភិបាលក្នុងការអនុវត្តន៍គំរោង បន្តអនុវត្តន៍គោលនយោបាយ NAPA បង្កើនកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នឯកជន និង កសិករ ក្នុងការចូលរួមស្តារហេដ្ឋារចនាសម្ព័ន្ធ និងធារាសាស្ត្រ កិច្ចសហការពីម្ចាស់ជំនួយនិងដៃគូអភិវឌ្ឍន៍ក្នុងការផ្តល់ជំនួយអោយបានទៀងទាត់។

## សំនួរ_ចម្លើយ

***១. តើ NGO ជួយបង្កើតទីផ្សារអោយកសិករនៅលើផ្នែកណាខ្លះ? និងដោយមធ្យោបាយណា?***

**ចម្លើយ:** NGO ធ្វើការសំរបសំរួល និង ផ្តល់ព័ត៌មានទីផ្សារដល់កសិករ ផ្សារភ្ជាប់ទំនាក់ទំនងទៅទីផ្សារអន្តរជាតិ និង ចូលរួមជាមួយប្រជាជនដើម្បីបង្កើតទីផ្សារសហគមន៍។

២. តើ NGO ជួយជីកអណ្តូងអោយប្រជាជនគ្រប់ ២៤ ខេត្ត-ក្រុងឬទេ? បើអណ្តូងមានជាតិកំបោរតើ NGO នឹងដោះស្រាយយ៉ាងណា?

**ចម្លើយ:** NGO ធ្វើការជាមួយក្រសួង ឬ មន្ទីរជំនាញរបស់រដ្ឋាភិបាលដើម្បីធ្វើការរជីកអណ្តូង។ ចំពោះការថែទាំអណ្តូងគឺជាតួនាទី របស់សហគមន៍ និង អាជ្ញាធរប្រចាំតំបន់។

### ***២. បទបង្ហាញពីលទ្ធផលពិភាក្សារបស់ក្រុមកសិករ***

**កត្តាជោគជ័យ:** ទទួលបានចំណេះដឹងបច្ចេកទេសកសិកម្មថ្មីៗ ចេះជ្រើសរើសពូជ កែប្រែកសិកម្មតាមទំលាប់ចាស់ការធ្វើកសិកម្មចំរុះ ការបង្កើតសមាគមតូចៗដើម្បីជាផលប្រយោជន៍ដល់សហគមន៍ទាំងមូល គំនិតច្នៃប្រឌិតក្នុងការផលិតថ្នាំពុល និង ជីធម្មជាតិ និង ចំណេះដឹងផ្នែកការប្រែប្រួលអាកាសធាតុបើទោះបីជាពុំទាន់បានទូលំទូលាយ។

**បញ្ហាប្រឈម:** ខ្វះព័ត៌មានដើម្បីបង្កាជាមុន ខ្វះប្រព័ន្ធស្រោចស្រព ដីខ្សត់ជីជាតិ និង ដីរួមតូចដោយសារការរីកដុះដាលនៃទំហំគ្រួសារ និង រងការរំលោភបំពានដីធ្លី ពុំទាន់មានទំនុកចិត្តក្នុងការផ្លាស់ប្តូរទំលាប់ចាស់ ខ្វះពូជសមស្រប ការប្រាក់ខ្ពស់ ផលិតផលរបស់កសិករមានតម្លៃថោក ការចូលរួមនិងចំណេះដឹងរបស់ស្ត្រីនៅមានកំរិត និង ហេដ្ឋារចនាសម្ព័ន្ធជនបទពុំទាន់ឆ្លើយតបទៅនឹងតម្រូវការ។

**អនុសាសន៍:** ជំរុញការចូលរួមការអនុវត្តន៍ការងាររួមគ្នារវាងរដ្ឋាភិបាល វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងប្រជាជាន អនុវត្តន៍គោលនយោបាយគាំទ្រកសិករ ពង្រឹងសមត្ថភាពកសិករជំនាញប្រចាំសហគមន៍ និងការផលិតក្នុងស្រុក លើកកំពស់កសិកម្មសរីរាង្គ ប្រើឡជីវឧស្ម័ន្ទ ពង្រឹងការចូលរួមរបស់ស្ត្រីក្នុងការសំរេចចិត្ត ផ្លាស់ប្តូរទំលាប់ បង្កើនការផ្សព្វផ្សាយព័ត៌មានសំរាប់បង្កាជាមុនដល់កសិករ និង ផ្តល់ព័ត៌មានទីផ្សារ។

## សំនួរ_ចម្លើយ

*១. តើព័ត៌មានទីផ្សារអ្វីខ្លះដែលកសិករចង់បាន? ហើយកត្តាអ្វីខ្លះដែលនាំអោយផលិតផលកសិកម្មចុះថោក?*

កត្តាដែលធ្វើអោយដីខ្សោះជីជាតិ? កត្តានាំអោយខ្វះកំលាំងអូសទាញ? អ្វីខ្លះជាថ្នាំពុលធម្មជាតិ?

បង្កើនការសន្សំជីធម្មជាតិដោយវិធីណា? ការអនុវត្តន៍គោលនយោបាយគាំទ្រកសិករអ្វីខ្លះ?

**ចម្លើយ:** ព័ត៌មានអំពីថ្លៃទំនិញលើទីផ្សារជាក់ស្តែង កត្តាដែលនាំអោយយល់ថាតម្លៃផលិតផលរបស់កសិករចុះថោកគឺបណ្តាលមកពីតម្លៃទំនិញលើទីផ្សារឡើងថ្លៃ ប៉ុន្តែតម្លៃផលិតផលរបស់កសិករមួយចំនួនធំគឺនៅដដែល។ ដីខ្សោះជីជាតិដោយសារកត្តារាំងស្ងួត និង ការប្រើប្រាស់ជីគីមីលើសកំណត់។ ខ្វះកំលាំងអូសទាញដោយសារភាពក្រីក្រ។ ថ្នាំពុលធម្មជាតិផ្សំពី ផ្លែស្លែងស្លាក់ ទាប បណ្តូលពេជ្រ ដែលមិនប៉ះពាល់ដល់សុខភាព។ សូមអោយមានការអនុវត្តន៍គោលនយោបាយ ដូចជាគោលនយោបាយប្រើប្រាស់ជីគីមី និង ការចុះបញ្ជីដីធ្លីដែលប្រកបដោយតម្លាភាព។

**២. *សំណូមពរអោយកសិករនៅតំបន់ដែលមានទំលាប់ធ្វើស្រែមិនធ្វើភ្លឺ សូមលើកភ្លឺស្រែសំរាប់គ្រប់គ្រងទឹកដែលជួយដល់ការធ្វើស្រែ។***

### ៣. *បទបង្ហាញពីលទ្ធផលពិភាក្សារបស់ក្រុមរដ្ឋាភិបាល*

**កត្តាជោគជ័យ:** ស្ថាប័នរបស់រាជរដ្ឋាភិបាលមានការត្រៀមបង្កាជាមុន (ឧបករណ៍ សំភារ:)ក្នុងពេលមានគ្រោះមហន្តរាយ ស្ថាប័នជំនាញពាក់ព័ន្ធបានអប់រំផ្សព្វផ្សាយអំពីបញ្ហានិងផលប៉ះពាល់ពីអាកាសធាតុដល់ប្រជាពលរដ្ឋ បានផ្សព្វផ្សាយបច្ចេកទេសបន្សាំទៅនឹងបំរែបំរួលអាកាសធាតុដល់កសិករ មានការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធ។

**បញ្ហាប្រឈម:** ការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនលើការន្សាំទៅនឹងបំរែបំរួលអាកាសធាតុនៅមានកំរិត ប្រជាកសិករមិនទាន់ចូលរួមឱ្យបានល្អទូលំទូលាយ ខ្វះខាតមន្ត្រីជំនាញ និងមានមន្ត្រីមានសមត្ថភាពមួយចំនួនធ្វើការនៅក្រៅអង្គភាព ការទទួលយកព័ត៌មាន ចំណេះដឹង បច្ចេកទេសរបស់កសិករនៅមានកំរិត ខ្វះថវិកាសំរាប់ស្តារប្រព័ន្ធធារាសាស្ត្រ ការចូលរួមរបស់កសិករក្នុងការថែទាំសមិទ្ធផលនៅថ្នាក់មូលដ្ឋានផ្សេងៗនៅមានកំរិត (ប្រព័ន្ធធារាសាស្ត្រ ផ្លូវ ផ្តល់ក្តារព័ត៌មាន...)។

**អនុសាសន៍:** អនុវត្តន៍ការដឹកនាំនិងយន្តការសំរបសំរួលប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព ការចូលរួមនិងគាំទ្រពីគ្រប់អ្នកពាក់ព័ន្ធ កសាងធនធានមនុស្សពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ មានរចនាសម្ព័ន្ធការងារច្បាស់លាស់ មានផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពច្បាស់លាស់ កសិករចូលរួមអនុវត្តន៍ការន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនិងទទួលយកបច្ចេកទេសថ្មី។

**សំនួរ_ចម្លើយ**

១. ពីបច្ចុប្បន្នទៅអនាគតខាងមុខ តើរដ្ឋាភិបាលមានយុទ្ធសាស្ត្របែបណាដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ រវាងសហគមន៍ ដៃគូអភិវឌ្ឍន៍ និង ក្រសួងស្ថាប័នរដ្ឋាភិបាល?

២. ខ្ញុំឃើញថារដ្ឋាភិបាលបានចូលរួមបង្កើតទីផ្សារសំរាប់កសិករ ហេតុអ្វីក៏រដ្ឋាភិបាលមិនមានលើកឡើងពីបញ្ហាបង្កើតទីផ្សារសំរាប់ផលិតផលកសិកម្មរបស់ប្រជាកសិករ?

**ចម្លើយ:** និងធ្វើការរួមបញ្ចូល

៣. សូមជួយពន្យល់បន្ថែមពីបញ្ហាការងារត្រួតស៊ីគ្នាក្នុងការអនុវត្តន៍ការងាររបស់ក្រសួងរដ្ឋាភិបាល។

## III. របាយការណ៍បូកសរុប និង បិទកម្មវិធី

ក្រោមការចូលរួមពីសំណាក់ ឯកឧត្តម យឹម ឆៃលី ជាគណៈអធិបតីដើម្បីធ្វើការបិទកម្មវិធីនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ ឯកឧត្តម រ័ត្ន វីរៈ បានឡើងធ្វើសេចក្តីរាយការណ៍បូកសរុបលទ្ធផលនៃវេទិការរយៈពេលពីរថ្ងៃនេះ។ ឯកឧត្តមបានលើកឡើងនូវចំនុចសំខាន់មួយចំនួនដូចខាងក្រោមៈ

វេទិកាថ្នាក់ជាតិលើកទី២នេះបានផ្តល់ឱកាសពិភាក្សាររវាងរដ្ឋាភិបាល កសិករ អ្នករៀបចំគោលនយោបាយ និង អ្នកសំរេចចិត្តលើបញ្ហាការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ពង្រឹងសមត្ថភាពកសិករក្នុងការបន្សុាំនឹងបម្រែបម្រួលអាកាសធាតុ និង បញ្ជ្រាបគោលនយោបាយ NAPA ដើម្បីចូលរួមកាត់បន្ថយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ឯកឧត្តមបានលើកឡើងនូវ សំណូមពរសំខាន់ៗមួយចំនួនដែលជាលទ្ធផលនៃកិច្ចពិភាក្សាៈ សូមបន្តការផ្សព្វផ្សាយចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ បណ្តុះបណ្តាលបច្ចេកទេស និងបង្កើតនូវឧបករណ៏កសិកម្មដែលអាចជួយដល់កសិករក្នុងការបន្សុាំ ទប់ស្កាត់ការរំលោភបំពានយកដី ប្រជាជន ជំរុញការផ្លាស់ប្តូរឥរិយាបទក្នុងការធ្វើកសិកម្ម អនុវត្តន៏ប្រព័ន្ធកសិកម្មចំរុះ សូមអោយមានការពិភាក្សាជាមួយកសិករ មុននិងធ្វើសេចក្តីសំរេចចិត្ត បង្កើនការស្រាវជ្រាវនិងផ្សព្វផ្សាយនូវបញ្ហាអាកាសធាតុតាមរយៈ ទូរទស្សន៏ និង វិទ្យុ បន្តកសាង ប្រព័ន្ធធារាសាស្រ្ត សូមបន្តរៀបចំវេទិកានេះតទៅទៀត ធ្វើទំនប់ទឹកប្រែបន្ថែម អប់រំកសិករអោយចេះគណនេយ្យសាមញ្ញ និង វិភាគសេដ្ឋកិច្ចសាមញ្ញ បន្តលើកកំពស់ស្រ្តី និងកុមារ ជំរុញការដាំដំណាំចំរុះ បង្កើតសមាគមសន្សំប្រាក់ បង្កើននិងទាក់ទាញ វិនិយោគទន់ដែលផ្តល់ប្រយោជន៏ដល់សហគមន៏ និង ផ្តល់កម្ចីដល់កសិករដោយផ្ទាល់ដែលមានការប្រាក់ទាប ។

បន្ទាប់ពីរបាយការណ៏បូកសរុបរបស់ឯកឧត្តម រ័ត្ន វីរៈ រួចមក ឯកឧត្តម យឹម ឆៃលី បានធ្វើបទសុន្ទរកថាបិទអង្គវេទិកាកសិករថ្នាក់ជាតិលើកទី២ ឯកឧត្តមបានមានមតិចាប់អារមណ៏ថា ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាសកល និងត្រូវការការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការកាត់បន្ថយ និង បន្សុាំ កម្ពុជាជាប្រទេសមួយដែលងាយទទួលរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ដោយសារបច្ចុប្បន្នកម្ពុជាបានចាត់ទុកវិស័យកសិកម្មជាកត្តាសំខាន់ក្នុងការអភិវឌ្ឍន៏សេដ្ឋកិច្ចជាតិ ដូច្នេះហើយកម្ពុជាត្រូវពង្រឹងសមត្ថភាពអោយបានសមស្របដើម្បីទប់ទល់នឹងបញ្ហានេះ ជាពិសេសដើម្បីជួយដល់កសិករខ្នាតតូចអោយពួកគាត់អាចបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុបានល្អ។ ក្នុងនាមកម្ពុជាជាសមាជិកអនុវត្តន៏អនុសញ្ញា UNFCCC និង ក្យូតូ រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាដើម្បីអនុវត្តន៏ក្របខ័ណ្ឌអង្គការសហប្រជាជាតិនេះអោយបានល្អប្រសើរ។ កន្លងមកការចូលរួមពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល កសិករ និង បណ្តាវិស័យឯកជននានាពិតជានាំមកនូវភាពជោគជ័យយ៉ាងច្រើនដល់ការអភិវឌ្ឍន៏សេដ្ឋកិច្ចជាតិ និង ឈានទៅកាត់បន្ថយភាពក្រីក្រទៅតាមទិសដៅរបស់រដ្ឋាភិបាល ១% ក្នុង១ឆ្នាំ និង អោយមានកំណើនសេដ្ឋកិច្ច ៧% ក្នុង១ឆ្នាំ។ ក្នុងនាមរដ្ឋាភិបាល ឯកឧត្តមសំណូមពរអោយអង្គការក្រៅរដ្ឋាភិបាលបន្តជួយដល់កសិករខ្នាតតូចបន្តទៀតក្នុង ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ទន្ទឹមនឹងភាពជោគជ័យទាំងនេះ រដ្ឋាភិបាលក៏ទទួស្គាល់ផងដែរនូវបញ្ហាប្រឈមមួយចំនួនដែលកំពុងជួបប្រទះដូចជា ធនធានមនុស្សនៅមានក៏រិត ការស្រាវជ្រាវពុំទាន់បានទូលំទូលាយ ខ្វះខាតថវិកា និង ការចូលរួមពីអ្នកដែលពាក់ព័ន្ធ និង កសិករនៅមានក៏រិតក្នុងការអនុវត្តន៏គំរោងបន្សុាំ។ ឆ្លើយតបនឹងបញ្ហានេះ ឯកឧត្តមក៏បានលើកឡើងនូវអនុសាសន៏មួយចំនួនខាងក្រោមៈ

- កសិករត្រូវធ្វើការផ្លាស់ប្តូរទំលាប់ និង ទទួលយកនូវបច្ចេកវិទ្យាថ្មីៗដែលជួយដល់ការបន្សុាំ
- ធ្វើការរួមគ្នា និង ចែករំលែកចំណេះដឹង និង បទពិសោធន៏ទាក់ទិននឹងការបន្សុាំ
- ក្រសួងពាក់ព័ន្ធទាំងឡាយគួរបញ្ចូលបញ្ហាការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៏ និង ការអនុវត្តន៏គំរោង

នានា និង បន្តលើកកំពស់ស្ត្រីក្នុងការងារអភិវឌ្ឍន៍ និង ការសំរេចចិត្ត

- ដៃគូអភិវឌ្ឍន៍ត្រូវបន្តជួយជាមូលនិធិអោយបានទៀងទាត់និងមានរយៈពេលសមស្របដើម្បីអនុវត្តន៍គំរោងប្រកបដោយប្រសិទ្ធភាព និង ជួយបំពេញបន្ថែមនូវចំនុចខ្វះចន្លោះរបស់រដ្ឋាភិបាលក្នុការផ្តល់សេវាកម្មសាធារណៈ និង ភ្ជាប់ព័តិមាន ពីពលរដ្ឋដល់រដ្ឋាភិបាល
- វិស័យឯកជនត្រូវជួយបង្កើតនូវសមិទ្ធិផលថ្មីៗ ជួយកសិករនូវបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ ធារាសាស្ត្រសំរាប់ប្រជាកសិករធ្វើការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ និង បង្កើនការវិនិយោគដើម្បីពង្រីកទីផ្សារការងារ ។

ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណដល់អង្គពិធីទាំងមូលដែលបានពាំនាំមកនូវលទ្ធផលជាផ្លែផ្ការ ដើម្បីជួយដល់កសិករខ្នាតតូចក្នុងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ឯកឧត្តមប្រកាសបិទអង្គវេទិកានៅម៉ោង ៥:១៥នាទី ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១។

***សូមអរគុណ!***